**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៧/០០៧ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ ១៨អនក្រ-បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០០៨

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់ការគ្រប់គ្រង និងបទដ្ឋានបច្ចេកទេសជួសជុល និងកែច្នៃដំឡើងយានយន្ត នៃយានដ្ឋានទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ ៖

- ពង្រឹងការគ្រប់គ្រង និងលើកកម្ពស់សមត្ថភាពបច្ចេកទេសយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត ឱ្យអនុវត្តតាមបទដ្ឋានបច្ចេកទេសត្រឹមត្រូវ តាមស្តង់ដារអន្តរជាតិ
- ធ្វើការបែងចែកច្បាស់លាស់ រវាងយានយន្តកែច្នៃក្នុងស្រុក និងយានយន្តនាំចូល ដែលជាកត្តាកំណត់នូវប្រភពរបស់យានយន្ត និងធានានូវភាពងាយស្រួល ក្នុងការផ្តល់ប័ណ្ណសម្គាល់យានយន្ត និងផ្លាកលេខយានយន្ត ជូនម្ចាស់យានយន្តបានត្រឹមត្រូវតាមច្បាប់
- រួមចំណែកថែរក្សា ការពារហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងស្ពាន
- រួមចំណែកថែរក្សាសណ្តាប់ធ្នាប់សង្គម សុវត្ថិភាពចរាចរណ៍ និងបរិស្ថាន
- បង្កើតការងារ ផ្តល់ជំនាញបច្ចេកទេស និងជំរុញគំនិតច្នៃប្រឌិត របស់អ្នកបច្ចេកទេសខាងយន្តសាស្ត្រ ឱ្យកាន់តែប្រសើរ ។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាព គ្របដណ្តប់លើគ្រប់ទីតាំងយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្តគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងគ្រឿងយន្តកសិកម្ម ។

**មាត្រា ៤.-**

វាក្យស័ព្ទ ដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវកំណត់និយមន័យដូចតទៅ ៖

- យានដ្ឋានជួសជុលយានយន្ត សំដៅដល់ទីតាំងប្រកបអាជីវកម្មជួសជុលយានយន្ត រ៉ឺម៉ក ឬសឺមីរ៉ឺម៉ក ដែលផ្នែកណាមួយត្រូវបានខូច ឬដំណើរការមិនធម្មតា ហើយត្រូវជួសជុលផ្នែកនោះ ឱ្យមានដំណើរការឡើងវិញ
- យានដ្ឋានកែច្នៃដំឡើងយានយន្ត សំដៅដល់ទីតាំងប្រកបអាជីវកម្មកែច្នៃដំឡើងយានយន្ត ដោយប្រមូលផ្នែកផ្សេងៗនៃយានជំនិះ ដែលប្រើប្រាស់ហើយ ឬថ្មីមកផ្គុំគ្នាបង្កើតជាយានយន្ត រ៉ឺម៉ក ឬសឺមីរ៉ឺម៉ក ដើម្បីចរាចរណ៍លើផ្លូវថ្នល់
- យានយន្ត សំដៅដល់យាន ដែលធ្វើចរាចរដោយម៉ាស៊ីននៅលើផ្លូវ ដូចជាម៉ូតូកង់បី ត្រីចក្រយានយន្ត រថយន្ត ត្រាក់ទ័រ គោយន្ត និងយានយន្តឧបករណ៍ ។
- រ៉ឺម៉ក សំដៅដល់យាន ដែលផ្តាក់ជាប់នឹងរថយន្ត ឬទោចក្រយានយន្ត
- សឺមីរ៉ឺម៉ក សំដៅដល់យាន ដែលផ្តាក់ជាប់នឹងក្បាលរថយន្តសណ្តោង
- យានជំនិះ សំដៅដល់យានគ្រប់ប្រភេទសម្រាប់ដឹកមនុស្ស ឬទំនិញ ឬសម្រាប់សណ្តោង ឬត្រូវតែសណ្តោង
- រថយន្តកសិកម្មកែច្នៃ សំដៅដល់យានយន្តកែច្នៃដំឡើង សម្រាប់ដឹកកសិផល ឬទំនិញផ្សេងៗ
- គោយន្តភ្ជួររាស់ សំដៅដល់យានយន្ត ដែលប្រើប្រាស់សម្រាប់ភ្ជួររាស់ស្រែចំការ ឬ[illegible] ដឹកកសិផល ឬទំនិញផ្សេងៗ ។

## ជំពូកទី ២
## សមត្ថកិច្ចគ្រប់គ្រងយានដ្ឋាន

**មាត្រា ៥.-**

ក្រសួងសាធារណការ និងដឹកជញ្ជូន ឬមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង មានសមត្ថកិច្ចក្នុងការគ្រប់គ្រង ចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីឆ្លើយតបទៅនឹងគោលបំណង ដូចមានចែងក្នុងមាត្រា ២ នៃអនុក្រឹត្យនេះ ។ ក្រសួងសាធារណការ និង ដឹកជញ្ជូន ឬមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង ត្រូវផ្តល់របាយការណ៍ និងឯកសារចុះបញ្ជី ជូនទៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត ក្រុង ក្រោយពីចុះបញ្ជីរួចហើយ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវកំណត់បែងចែកសិទ្ធិគ្រប់គ្រង ទៅតាមទំហំនៃយានដ្ឋាន ដូចខាងក្រោម ÷

- ទំហំយានដ្ឋានលើសពី ២៥០ ម៉ែត្រការ៉េឡើងទៅ ត្រូវមានការអនុញ្ញាត ពីក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីធ្វើអាជីវកម្មជួសជុល និងកែច្នៃដំឡើងយានយន្ត
- ទំហំយានដ្ឋានតិចជាងឬស្មើ ២៥០ ម៉ែត្រការ៉េ ត្រូវមានការអនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋានជួសជុល និងកែច្នៃដំឡើងយានយន្ត ពីមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង ។

**មាត្រា ៧.-**

ការត្រួតពិនិត្យលើយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត ជាសមត្ថកិច្ចរបស់ក្រុមមន្ត្រីជំនាញ ដែលមានបទពិសោធន៍ នៃក្រសួងសាធារណការ និងដឹកជញ្ជូន និងក្នុងករណីចាំបាច់ ត្រូវមានការត្រួតពិនិត្យពីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៣
## លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋាន

**មាត្រា ៨.-**

ជនជាតិខ្មែរ ឬជនបរទេស ជារូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងធ្វើអាជីវកម្មយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត ត្រូវបំពេញលក្ខខណ្ឌដូចតទៅ ÷

- ត្រូវមានវិស្វករ ឬអ្នកបច្ចេកទេសជំនាញយានយន្តម្នាក់ ទទួលខុសត្រូវលើបច្ចេកទេសយានយន្ត និងមានបទពិសោធន៍ ការងារយានយន្ត យ៉ាងតិច ២(ពីរ)ឆ្នាំ
- មានទីតាំងសមរម្យតាមនិយាមនៃបទដ្ឋានបរិស្ថាន និង មានការអនុញ្ញាតពីអាជ្ញាធរដែនដីមានសមត្ថកិច្ច
- មានសម្ភារបរិក្ខារសម្រាប់បម្រើអាជីវកម្មរបស់ខ្លួនគ្រប់គ្រាន់ តាមបទដ្ឋានបច្ចេកទេស ។

**មាត្រា ៩.-**

ជនជាតិខ្មែរ ឬជនបរទេសជារូបវន្តបុគ្គល ឬនីតិបុគ្គល ដែលធ្វើអាជីវកម្មយានដ្ឋានជួសជុល ឬយានដ្ឋានកែច្នៃដំឡើងយានយន្ត ត្រូវគោរពតាមច្បាប់ និងបទប្បញ្ញត្តិនានារបស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១០.-**

សំណុំបែបបទ សម្រាប់ដាក់ពាក្យសុំលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត និងលិខិតស្នាមផ្សេងៗទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ១១.-**

លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋានជួសជុល ឬយានដ្ឋានកែច្នៃដំឡើងយានយន្ត មួយច្បាប់ ផ្តល់សម្រាប់យានដ្ឋាន តែមួយកន្លែងប៉ុណ្ណោះ ។

ការធ្វើអាជីវកម្មយានដ្ឋានជួសជុល ឬយានដ្ឋានកែច្នៃដំឡើងយានយន្ត អាចលក់ ឬផ្ទេរបន្ត ទៅឱ្យបុគ្គលផ្សេងទៀតបាន ដោយត្រូវស្នើសុំមកក្រសួងសាធារណការ និងដឹកជញ្ជូន ឬមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង ដើម្បីពិនិត្យ និងសម្រេច ។

**មាត្រា ១២.-**

លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋានជួសជុល ឬយានដ្ឋានកែច្នៃដំឡើងយានយន្ត មានសុពលភាពប្រើប្រាស់រយៈពេល ២(ពីរ)ឆ្នាំ ។ ម្ចាស់យានដ្ឋាន ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មបន្តឡើងវិញទៀត ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ យ៉ាងយូរបំផុត មុនអស់សុពលភាព មកក្រសួងសាធារណការ និងដឹកជញ្ជូន ឬមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង ។ ក្នុងរយៈពេលនេះ ម្ចាស់យានដ្ឋាននៅតែមានសិទ្ធិបន្តធ្វើសកម្មភាពរហូតដល់ថ្ងៃ ដែលក្រសួងសាធារណការ និងដឹកជញ្ជូន ឬមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង សម្រេចជាថ្មី ។

អាជីវករ ដែលទទួលបានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មរួចហើយ តែមិនមានសកម្មភាពអ្វីសោះក្នុងរយៈពេល ៦(ប្រាំមួយ)ខែ គិតចាប់តាំងពីថ្ងៃ ដែលបានចុះហត្ថលេខាហើយនោះ ក្រសួងសាធារណការ និងដឹកជញ្ជូន ឬមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង ចាត់ទុកលិខិតអនុញ្ញាតនោះ ជាមោឃៈ ។

**មាត្រា ១៣.-**

ថ្លៃសេវាកម្មចុះបញ្ជី ផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត នៅគ្រាដំបូង ឬបន្តឡើងវិញ ឬផ្ទេរ និងថ្លៃផ្សេងៗ ត្រូវកំណត់ដោយប្រកាសរួម របស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៤

## បទដ្ឋានបច្ចេកទេសក្នុងការជួសជុល និងកែច្នៃដំឡើងយានយន្ត

**មាត្រា ១៤.-**

ការជួសជុលយានយន្ត ត្រូវរក្សាអត្តសញ្ញាណដើមសម្គាល់យានយន្ត ដូចជា លេខតួ លេខកាប៊ីន លេខសាក់ស៊ី លេខម៉ាស៊ីន ពណ៌ និងប្រភេទយានយន្ត ។ ក្នុងករណីដែលអត្តសញ្ញាណសម្គាល់ណាមួយ ត្រូវប្រែប្រួលដោយប្រការណាមួយ ម្ចាស់យានដ្ឋាន ត្រូវដាក់ពាក្យសុំការសម្រេចពីក្រសួងសាធារណការ និងដឹកជញ្ជូន ឬមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង ដើម្បីបង្កើតអត្តសញ្ញាណសម្គាល់ ជាថ្មីឡើងវិញ ។ រាល់ការជួសជុលម្ចាស់យានដ្ឋានត្រូវចេញវិក័យបត្រជូនម្ចាស់យានយន្ត ។

**មាត្រា ១៥.-**

រាល់ការកែច្នៃដំឡើងយានយន្ត ម្ចាស់យានដ្ឋាន ត្រូវមានលិខិតបញ្ជាក់ពីប្រភពនៃគ្រឿងបន្លាស់[illegible] និងធានាឱ្យបានត្រឹមត្រូវតាមលក្ខណបច្ចេកទេស នៃផ្នែកនីមួយៗ របស់យានយន្ត ដែលបានកែច្នៃដំឡើងរួច[illegible] ដែល ត្រូវយកមកកែច្នៃ អាចបានពីរបស់ ឬផ្នែកផ្សេងៗ ដែលមានក្នុងស្រុក ឬបានមកពីការនាំចូល[illegible] អាចប្រើប្រាស់បានយ៉ាងតិច ៨០% ។ គ្រឿងបន្លាស់ ឬផ្នែកផ្សេងៗ ដែលប្រមូលបាននៅក្នុងស្រុក[illegible] ក្នុងសក្ខីបត្រ ដូចជាបានមកពីការលុបបញ្ជីយានយន្តរបស់រដ្ឋជាដើម ។

លិខិតបញ្ជាក់ពីប្រភពនៃគ្រឿងបន្លាស់ ទាំងក្នុងស្រុក ឬនាំចូល ដែលបានមកដើម្បី[illegible]យានយន្ត

និងវិក័យបត្រកែច្នៃដំឡើងយានយន្ត ម្ចាស់យានដ្ឋានត្រូវរក្សាទុករយៈ ៥(ប្រាំ) ឆ្នាំ ដើម្បីត្រួតពិនិត្យដោយប្រការណាមួយ ។

រាល់ការកែច្នៃដំឡើងយានយន្ត ម្ចាស់យានដ្ឋាន ត្រូវចេញវិក័យបត្រជូនម្ចាស់យានយន្ត ។

**មាត្រា ១៦.-**

ក្នុងការកែច្នៃដំឡើង ហាមកាត់តសាក់ស៊ីរថយន្ត ឬកាត់តប្រព័ន្ធចង្កូតរថយន្ត ។ ចំពោះការកែច្នៃដំឡើងផ្នែកណាមួយ ដែលជាកត្តាធ្វើឱ្យយានយន្ត ពុំអាចធានាសុវត្ថិភាពបាន ត្រូវកំណត់ក្នុងប្រកាស របស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ។

ចំពោះផ្លាកលេខ និងប័ណ្ណសម្គាល់ ដែលនៅសល់ពីការដោះរុះរើយានយន្ត ដែលត្រូវយកមកកែច្នៃដំឡើងនោះ ម្ចាស់យានដ្ឋាន ត្រូវផ្ញើមកក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីធ្វើការជម្រះបញ្ជី ។

**មាត្រា ១៧.-**

ការកែច្នៃដំឡើងយានយន្ត ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេស ដូចមានចែងក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ ។

**មាត្រា ១៨.-**

ទំហំយានយន្ត ដែលកែច្នៃដំឡើង ត្រូវកំណត់យកតាមតារាងដូចខាងក្រោម :

| ប្រភេទយានយន្ត | បណ្តោយ (ប) | ទទឹង (ទ) | កម្ពស់ (ក) |
|---|---|---|---|
| រថយន្តដឹកតូច | ប ≤ ៦,៥ម៉ែត្រ | ទ ≤ ២,៥ម៉ែត្រ | ក ≤ ២,៥ម៉ែត្រ |
| រថយន្តដឹកធំ | ប ≤ ១២,២ម៉ែត្រ | ទ ≤ ២,៥ម៉ែត្រ | ក ≤ ៤,២ម៉ែត្រ |
| រថយន្តសណ្តោងសឺមីរ៉ឺម៉ក | ប ≤ ១៦ម៉ែត្រ | ទ ≤ ២,៥ម៉ែត្រ | ក ≤ ៤,២ម៉ែត្រ |
| រថយន្តសណ្តោងរ៉ឺម៉ក | ប ≤ ១៨ម៉ែត្រ | ទ ≤ ២,៥ម៉ែត្រ | ក ≤ ៤,២ម៉ែត្រ |

**មាត្រា ១៩.-**

ការកែច្នៃដំឡើងយានយន្ត ដែលពុំមានការកំណត់ ដូចមាត្រា១៧ និងមាត្រា១៨ នៃអនុក្រឹត្យនេះ ម្ចាស់យានដ្ឋាន ត្រូវដាក់ពាក្យសុំការអនុញ្ញាតពីក្រសួងសាធារណការ និងដឹកជញ្ជូន ដោយត្រូវភ្ជាប់នូវប្លង់ដំឡើងយានយន្តប្រភេទនេះមកជាមួយ ។

**មាត្រា ២០.-**

ការកែច្នៃដំឡើងប្រព័ន្ធម៉ាស៊ីន ដែលត្រូវភ្ជាប់បន្ថែមនូវបរិក្ខារផ្សេងទៀត ក្នុងគោលបំណងកាត់បន្ថយ ការប្រើប្រាស់ប្រេងឥន្ធនៈ ឬភ្ជាប់ប្រព័ន្ធប្រើប្រាស់ឧស្ម័ន ម្ចាស់យានដ្ឋាន ត្រូវសុំការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ២១.-**

ប្រភេទត្រីចក្រយានយន្ត ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក គោយន្តភ្ជួររាស់ និងរថយន្តកសិកម្មកែច្នៃ ដែលបានកែច្នៃដំឡើង ត្រូវកំណត់ដូចខាងក្រោម ÷

- ត្រីចក្រយានយន្ត ដូកទំនិញ ឬដូកបណ្តោយយាន ប្រភេទទី ១ (ឧបសម្ព័ន្ធទី ២)
- ត្រីចក្រយានយន្ត ដូកទំនិញ ឬដូកបណ្តោយយាន ប្រភេទទី ១ (ឧបសម្ព័ន្ធទី ៣)
- ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ប្រភេទទី ១ (ឧបសម្ព័ន្ធទី ៤)
- ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ប្រភេទទី ២ (ឧបសម្ព័ន្ធទី ៥)
- គោយន្តភ្ជួររាស់សណ្តោងរ៉ឺម៉ក និងរថយន្តកសិកម្មកែច្នៃ (ឧបសម្ព័ន្ធទី ៦)

**មាត្រា ២២.-**

ត្រឹចក្រយានយន្ត និងរទោចក្រយានយន្តសណ្ដោងរ៉ឺម៉ក (ឧបសម្ព័ន្ធទី២, ទី៣, ទី៤ និងទី៥) ត្រូវមានលក្ខណៈបច្ចេកទេសទូទៅ ដូចខាងក្រោម ÷

- កញ្ចក់មើលក្រោយ
- ប្រព័ន្ធហ្វ្រាំងមានប្រសិទ្ធភាព
- ភ្លើងបំភ្លឺ : ភ្លើងហ្វា-កូត ភ្លើងក្រហម ភ្លើងសញ្ញាប្ដូរទិសមុខ-ក្រោយ និងកញ្ចក់ចាំងពន្លឺ
- សូរស៊ីផ្លេស្លង់ដារទោចក្រយានយន្ត មិនឱ្យលើសពី ៩៩ ដេស៊ីបែល dB(A)
- ទំហំត្រឹចក្រយានយន្ត និងរទោចក្រយានយន្តសណ្ដោងរ៉ឺម៉ក ត្រូវកំណត់យកដូចខាងក្រោមនេះ :

| ប្រភេទយានយន្ត | បណ្ដោយ (ប) | ទទឹង (ទ) | កម្ពស់ (ក) |
|---|---|---|---|
| ត្រឹចក្រយានយន្ត ប្រភេទទី ១ | ប ≤ ៣,៣ម៉ែត្រ | ទ ≤ ១,៤ម៉ែត្រ | ក ≤ ២ម៉ែត្រ |
| ត្រឹចក្រយានយន្ត ប្រភេទទី ២ | ប ≤ ៤,៥ម៉ែត្រ | ទ ≤ ១,៥ម៉ែត្រ | ក ≤ ២,៥ម៉ែត្រ |
| រទោចក្រយានយន្តសណ្ដោងរ៉ឺម៉ក ប្រភេទទី ១ | ប ≤ ៣,៥ម៉ែត្រ | ទ ≤ ១,៤ម៉ែត្រ | ក ≤ ២ម៉ែត្រ |
| រទោចក្រយានយន្តសណ្ដោងរ៉ឺម៉ក ប្រភេទទី ២ | ប ≤ ៦,៥ម៉ែត្រ | ទ ≤ ១,៥ម៉ែត្រ | ក ≤ ២ម៉ែត្រ |

**មាត្រា ២៣.-**

គោយន្តក្អូររាស់សណ្ដោងរ៉ឺម៉ក (ឧបសម្ព័ន្ធទី ៦) ត្រូវមានលក្ខណៈបច្ចេកទេសទូទៅ ដូចខាងក្រោម÷

- ហ្វ្រាំងមានប្រសិទ្ធភាព
- ភ្លើងបំភ្លឺ : ភ្លើងកូត ភ្លើងក្រហម និងកញ្ចក់ចាំងពន្លឺ
- ទំហំគោយន្តក្អូររាស់សណ្ដោងរ៉ឺម៉ក ត្រូវកំណត់ដូចខាងក្រោមនេះ :

| ប្រភេទយានយន្ត | បណ្ដោយ (ប) | ទទឹង (ទ) | កម្ពស់ (ក) |
|---|---|---|---|
| គោយន្តក្អូររាស់សណ្ដោងរ៉ឺម៉ក | ប ≤ ៦,៥ម៉ែត្រ | ទ ≤ ២,៥ម៉ែត្រ | ក ≤ ២ម៉ែត្រ |

**មាត្រា ២៤.-**

រថយន្តកសិកម្មកែច្នៃ (ឧបសម្ព័ន្ធទី ៦) ត្រូវមានលក្ខណៈបច្ចេកទេសទូទៅ ដូចខាងក្រោម ÷

- កញ្ចក់មើលក្រោយ
- ប្រព័ន្ធហ្វ្រាំងមានប្រសិទ្ធភាព
- ភ្លើងបំភ្លឺ : ភ្លើងហ្វា-កូត ភ្លើងក្រហម ភ្លើងសញ្ញាប្ដូរទិសមុខ-ក្រោយ និងកញ្ចក់ចាំងពន្លឺ
- សូរស៊ីផ្លេ មិនឱ្យលើសពី ១១០ ដេស៊ីបែល dB(A)
- ទំហំរថយន្តកសិកម្មកែច្នៃ ត្រូវកំណត់ដូចខាងក្រោមនេះ :

| ប្រភេទយានយន្ត | បណ្ដោយ (ប) | ទទឹង (ទ) | កម្ពស់ (ក) |
|---|---|---|---|
| រថយន្តកសិកម្មកែច្នៃ | ប ≤ ៦,៥ម៉ែត្រ | ទ ≤ ២,៥ម៉ែត្រ | ក ≤ [illegible]ម៉ែត្រ |

**មាត្រា ២៥.-**

ការដាប់លេខតួ ឬលេខសាក់ស៊ី ឬលេខម៉ាស៊ីន របស់យានយន្តកែច្នៃដំឡើង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ។

មាត្រា ២៦._

ល្បឿនរថយន្តកសិកម្មកែច្នៃ កំណត់អតិបរមាត្រឹម ៥០គីឡូម៉ែត្រ/ម៉ោង ។

ល្បឿនគោយន្តភ្ជួររាស់សណ្តោងរ៉ឺម៉ក កំណត់អតិបរមាត្រឹម ៣០គីឡូម៉ែត្រ/ម៉ោង ។

មាត្រា ២៧._

យានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត ត្រូវមានវិធានការការពារសុវត្ថិភាពការងារ ថែរក្សាអនាម័យ និងការពារបរិស្ថាន ។

## ជំពូកទី ៥
## ការចុះបញ្ជីយានយន្តកែច្នៃដំឡើង

មាត្រា ២៨._

យានយន្ត ដែលបានកែច្នៃដំឡើងរួច ត្រូវរក្សាឱ្យបានស្អាត និងច្បាស់នូវលេខតួ លេខកាប៊ីន លេខសាក់ស៊ី ឬលេខម៉ាស៊ីន ដែលមានស្រាប់ ។

មាត្រា ២៩._

ចំពោះយានយន្ត ដែលបានកែច្នៃដំឡើងរួច គ្មានលេខតួ ឬលេខកាប៊ីន ឬលេខសាក់ស៊ី ឬលេខម៉ាស៊ីន ដោយមូលហេតុណាមួយ ម្ចាស់យានដ្ឋានត្រូវដាក់ពាក្យសុំមកក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីកំណត់យកប្រភេទលេខសម្រាប់យានយន្តទាំងនោះ ។

ក្នុងពាក្យសុំ ម្ចាស់យានដ្ឋាន ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ អំពីមូលហេតុ ដែលនាំឱ្យបាត់លេខដើមនោះ ។

មាត្រា ៣០._

ចំពោះយានយន្តកែច្នៃដំឡើង ដែលបានបំពេញកាតព្វកិច្ចបង់ពន្ធរួចហើយ ម្ចាស់យានដ្ឋានត្រូវយកយានយន្ត មកត្រួតពិនិត្យលក្ខណបច្ចេកទេស និងចុះបញ្ជីយានយន្តនៅក្រសួងសាធារណការ និងដឹកជញ្ជូន ឬមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្ត ក្រុង ។

មាត្រា ៣១._

ក្នុងករណីចាំបាច់ផ្សេងទៀត រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវចេញប្រកាសណែនាំបន្ថែម ។

## ជំពូកទី ៦
## ទោសប្បញ្ញត្តិ

មាត្រា ៣២._

ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណា ដែលអនុវត្តផ្ទុយពីខ្លឹមសារនៃអនុក្រឹត្យនេះ ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវមានវិធានការ ដូចខាងក្រោម ÷

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការបង់ប្រាក់ពិន័យផ្សេងៗ
- ការដកហូតលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋាន ក្នុងករណីមិនរាងចាល
- ការរៀបចំសំណុំលិខិតបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច ក្នុងករណីធ្ងន់ធ្ងរ ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

មាត្រា ៣៣._

ក្រោយរយៈពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃអនុក្រឹត្យនេះ ចូលជាធរមាន រាល់យានដ្ឋានជួសជុល និង

យានដ្ឋានកែច្នៃដំឡើងយានយន្ត ដែលមានច្បាប់អនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋានរួចហើយ ត្រូវសុំលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មបន្ត ពីក្រសួងសាធារណការ និងដឹកជញ្ជូន ឬពីមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង ។

**មាត្រា ៣៤.-**

ទំហំ និងលក្ខណបច្ចេកទេសរបស់រទេះក្រោយយានយន្តសណ្តោងរ៉ឺម៉កប្រភេទទី ២ ដែលកំណត់ក្នុង ឧបសម្ព័ន្ធទី ៥ មាត្រា ២១ នៃអនុក្រឹត្យនេះ ត្រូវអនុវត្តតាមការកំណត់ជាដំណាក់កាល ដូចខាងក្រោម ៖

ដំណាក់កាលទី ១ : ក្រោយរយៈពេល ៣(បី)ឆ្នាំ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន រទេះក្រោយយានយន្តសណ្តោងរ៉ឺម៉ក ត្រូវមានទំហំស៊ីឡាំងលើសពី ១២៥ សេសេឡើងទៅ ។ រ៉ឺម៉ក ត្រូវមានកៅអីពួកទទឹងយាន កំណត់ត្រឹមចំនួន៦ និងកៅអីពួកទីមួយ១ កំណត់សម្រាប់មនុស្ស ២នាក់ អង្គុយ ។ បើដឹកទំនិញ មិនត្រូវឱ្យលើសពី ១ (មួយ)តោន និងត្រូវអនុវត្តមាត្រា ៥៣ ចំណុច ៣ និង ៤ នៃច្បាប់ចរាចរណ៍ផ្លូវគោក ក្នុងករណីដឹកទំនិញវែង ។

ដំណាក់កាលទី ២ : ក្រោយរយៈពេល ៧(ប្រាំពីរ)ឆ្នាំ បន្ទាប់ពីដំណាក់កាលទី ១(មួយ) រទេះក្រោយយានយន្តសណ្តោងរ៉ឺម៉ក ដែលមានចែងក្នុងឧបសម្ព័ន្ធទី ៥ មាត្រា ២១ នៃអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៥.-**

ក្រសួងសាធារណការ និងដឹកជញ្ជូន មានភារកិច្ចផ្សព្វផ្សាយខ្លឹមសារនៃអនុក្រឹត្យនេះ ឱ្យបានគ្រប់ស្រទាប់ប្រជាជន ចាប់ពីអនុក្រឹត្យនេះ ចូលជាធរមាន ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងអភិបាលរាជធានី អភិបាលគ្រប់ខេត្ត ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យលេខ...១៩០.....អនក្រ.បក ចុះថ្ងៃទី..០៣....ខែវិច្ឆិកា ឆ្នាំ ២០០៨

ស្តីពី ការគ្រប់គ្រងយានដ្ឋានដឹកជញ្ជូន និងយានដ្ឋានកែច្នៃដំឡើងយានយន្ត

តារាងកំណត់ទម្ងន់សរុប ទម្ងន់អតិបរមាលើភ្លៅនីមួយៗ គម្លាតរវាងភ្លៅនីមួយៗ និងទម្ងន់សរុបលើភ្លៅភ្ជាប់

| ល.រ | ប្រភេទយានយន្ត | ទម្ងន់សរុប (តោន) | ទម្ងន់លើភ្លៅនីមួយៗ (តោន) | | | | | | គម្លាតរវាងភ្លៅនីមួយៗ (ម៉ែត្រ) | | | | | ទម្ងន់សរុបលើភ្លៅភ្ជាប់ (តោន) | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4 | 5 | 6 | A | B | C | D | E | 1 | 2 |
| 1 | រថយន្តទេសចរណ៍(ក) | 1,82 | 0,87 | 0,95 | | | | | 2,3 – 2,8 | | | | | | |
| 2 | រថយន្តទេសចរណ៍ (ខ) | 2,90 | 1,20 | 1,70 | | | | | 2,2 – 3,0 | | | | | | |
| 3 | រថយន្តដឹកទំនិញធុនតូច | 2,70 | 1,25 | 1,45 | | | | | 2,3 – 3,1 | | | | | | |
| 4 | រថយន្តដឹកអ្នកដំណើរ (១២-១៥កៅអី) | 2,80 | 1,35 | 1,45 | | | | | 2,3 – 2,7 | | | | | | |
| 5 | រថយន្តដឹកអ្នកដំណើរ (២៣-៣៥កៅអី) | 7,50 | 2,75 | 4,75 | | | | | 3,8 – 4,4 | | | | | | |
| 6 | រថយន្តដឹកអ្នកដំណើរ (៤០-៥៥កៅអី) | 12,0 | 2,90 | 9,10 | | | | | 4,2 – 6,8 | | | | | | |
| 7 | រថយន្តដឹកទំនិញធុនស្រាល | 8,50 | 1,70 | 6,80 | | | | | 2,3 – 3,4 | | | | | | |
| 8 | រថយន្តដឹកទំនិញធុនធ្ងន់ ប្រភេទទី១ | 12,0 | 2,90 | 9,10 | | | | | 3,0 – 6,0 | | | | | | |

| ល.រ | ប្រភេទយានយន្ត | | ទម្ងន់សរុប (តោន) | ទម្ងន់លើភ្លៅនីមួយៗ (តោន) | | | | | | ចន្លោះចម្ងាយរវាងភ្លៅនីមួយៗ (ម៉ែត្រ) | | | | | ទម្ងន់សរុបលើភ្លៅរួម (តោន) | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4 | 5 | 6 | A | B | C | D | E | 1 | 2 |
| 9 | រថយន្តដឹកទំនិញធុនធ្ងន់ ប្រភេទទី២ |  | 21,0 | 4,60 | 8,20 | 8,20 | | | | 3,0 – 7,0 | 1,1 – 1,4 | | | | 16,4 | |
| 10 | រថយន្តដឹកទំនិញធុនធ្ងន់ ប្រភេទទី៣ |  | 23,90 | 2,90 | 4,60 | 8,20 | 8,20 | | | 1,7 – 2,0 | 3,0 – 5,0 | 1,1 – 1,4 | | | 16,4 | |
| 11 | រថយន្តដឹកទំនិញធុនធ្ងន់សណ្តោងរ៉ឺម៉ក ប្រភេទទី១ |  | 21,10 | 2,90 | 9,10 | 9,10 | | | | 3,0 – 6,0 | 3,0 – 4,5 | | | | | |
| 12 | រថយន្តដឹកទំនិញធុនធ្ងន់សណ្តោងរ៉ឺម៉ក ប្រភេទទី២ |  | 30,10 | 4,60 | 8,20 | 8,20 | 9,10 | | | 3,0 – 7,0 | 1,1 – 1,4 | 3,0 – 4,5 | | | 16,4 | |
| 13 | រថយន្តដឹកទំនិញធុនធ្ងន់ សណ្តោងរ៉ឺម៉ក ប្រភេទទី៣ |  | 30,20 | 2,90 | 9,10 | 9,10 | 9,10 | | | 3,0 – 6,0 | 3,0 – 4,5 | 3,0 – 5,0 | | | | |
| 14 | រថយន្តដឹកទំនិញធុនធ្ងន់ សណ្តោងរ៉ឺម៉ក ប្រភេទទី៤ |  | 39,20 | 4,60 | 8,20 | 8,20 | 9,10 | 9,10 | | 3,0 – 7,0 | 1,1 – 1,4 | 3,0 – 4,5 | 3,0 – 5,0 | | 16,4 | |
| 15 | រថយន្តសណ្តោងសឺមីរ៉ឺម៉ក ប្រភេទទី១ |  | 21,10 | 2,90 | 9,10 | 9,10 | | | | 3,0 – 4,0 | 4,0 [illegible] | | | | | |
| 16 | រថយន្តសណ្តោងសឺមីរ៉ឺម៉ក ប្រភេទទី២ |  | 30,20 | 2,90 | 9,10 | 8,20 | 8,20 | | | 3,0 – 4,0 | 4,[illegible] | | | | | 16,4 |
| 17 | រថយន្តសណ្តោងសឺមីរ៉ឺម៉ក ប្រភេទទី៣ |  | 30,10 | 4,60 | 8,20 | 8,20 | 9,10 | | | 3,0 – 5,0 | 1,1 – 1,4 | | | | 16,4 | |

| ល.រ | ប្រភេទយានយន្ត | | ទម្ងន់សរុប (តោន) | ទម្ងន់លើភ្លៅនីមួយៗ (តោន) | | | | | | ចន្លោះចម្ងាយរវាងភ្លៅនីមួយៗ (ម៉ែត្រ) | | | | | ទម្ងន់សរុបលើភ្លៅភ្លោះ (តោន) | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4 | 5 | 6 | A | B | C | D | E | 1 | 2 |
| 18 | រថយន្តសណ្តោងសីមី រ៉ឺម៉ក ប្រភេទ១៤ |  | 37,40 | 4,60 | 8,20 | 8,20 | 8,20 | 8,20 | | 3,0 – 5,0 | 1,1 – 1,4 | 4,0 – 5,0 | 1,1 – 1,4 | | 16,4 | 16,4 |
| 19 | រថយន្តសណ្តោងសីមី រ៉ឺម៉ក ប្រភេទ១៥ |  | 33,60 | 2,9 | 9,10 | 7,20 | 7,20 | 7,20 | | 3,0 – 4,0 | 4,0 – 5,0 | 1,1 – 1,4 | 1,1 – 1,4 | | | 21,6 |
| 20 | រថយន្តសណ្តោងសីមី រ៉ឺម៉ក ប្រភេទ១៦ |  | 42,60 | 4,60 | 8,20 | 8,20 | 7,20 | 7,20 | 7,2 | -3,0 – 5,0 | 1,1 – 1,4 | 4,0 – 5,0 | 1,1 – 1,4 | 1,1 – 1,4 | 16,4 | 21,6 |

កំណត់សម្គាល់: ○ កង់ទោល ◉ កង់ភ្លោះ

| | |
|---|---|
| កន្ទុយក្រោយយាន<br>Rear over hang (ROH) |  |

**ឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យលេខ...............អនក្រ.បក ចុះថ្ងៃទី...........ខែ...........ឆ្នាំ ២០០..**

**ស្តីពី ការគ្រប់គ្រងយានយន្តរ៉ឺម៉ក់ម៉ូតូ និងយានយន្តកង់បីប្រើម៉ាស៊ីនយានយន្ត**

**ត្រឹមត្រូវតាមបច្ចេកទេសពិសេស ទម្រង់របស់យាន ប្រភេទនេះ**



ឧបសម្ព័ន្ធទី ៣ នៃអនុក្រឹត្យលេខ..............អនក្រ.បក ចុះថ្ងៃទី.........ខែ..........ឆ្នាំ ២០០..

ស្តីពី ការគ្រប់គ្រងយានជំនិះម៉ូតូសណ្តោងរ៉ឺម៉ក និងយានជំនិះកង់បីប្រើម៉ាស៊ីន

គំរូរូបយានយន្តកង់បី ប្រភេទរ៉ឺម៉កយានយន្ត ប្រភេទទី ២



ឧបសម្ព័ន្ធទី ៤ នៃអនុក្រឹត្យលេខ..............អនក្រ.បក ចុះថ្ងៃទី..........ខែ..........ឆ្នាំ ២០០..

ស្តីពី ការគ្រប់គ្រងយានជំនិះដឹកអ្នកដំណើរ និងយានជំនិះដឹកទំនិញតភ្ជាប់រ៉ឺម៉កយានយន្ត

គោលរូបយានយន្តសណ្តោងរ៉ឺម៉ក ប្រភេទទី ១



**ឧបសម្ព័ន្ធទី ៥ នៃអនុក្រឹត្យលេខ................អនក្រ.បក ចុះថ្ងៃទី.........ខែ.........ឆ្នាំ ២០០..**

**ស្តីពី ការគ្រប់គ្រងយានជំនិះដឹកមនុស្ស និងយានជំនិះដឹកទំនិញដែលអូសដោយយានយន្ត**

**គោលគំរូយានយន្តសណ្ដោងរ៉ឺម៉ក ប្រភេទទី ២**






**ឧបសម្ព័ន្ធទី ៦ នៃអនុក្រឹត្យលេខ...១៥០.....អនក្រ.បក ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨**

**ស្តីពី ការគ្រប់គ្រងយានជំនិះជួសជុល និងយានជំនិះកែច្នៃជារ៉ឺម៉កយានយន្ត**

**ដោយប្រើគ្រឿងម៉ាស៊ីនទឹក និងតួយន្តកសិកម្មកែច្នៃ**



-ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី អំពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចរួចហើយ និង ពីវិធានការកែលំអការប្រព្រឹត្តទៅរបស់អង្គភាពទាំងនោះ

-ជាលេខាធិការរបស់ក្រសួង

-អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ជូន ។

អគ្គាធិការដ្ឋានដឹកនាំដោយអគ្គាធិការមួយរូប និងមានអគ្គាធិការរងមួយចំនួនជាជំនួយការ តាមការចាំបាច់ ។ រចនាសម្ព័ន្ធ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះអគ្គាធិការដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សូមឡាយព្រះហស្តលេខា
**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

**សូ ឃុន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៤
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ